ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី
លេខ:២០២៣/០០១ ជ.អ.ល.

# សេចក្តីជូនដំណឹង
## ស្តីពី
## ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី ទិញដីសម្រាប់អភិវឌ្ឍន៍គម្រោង THE GARDEN RESIDENCY 3

ក្រុមហ៊ុន **ជេអេស លែន ភីអិលស៊ី (ជ.អ.ល.)** គឺជាក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យដំបូងគេក្នុងព្រះរាជាណាចក្រកម្ពុជាដែលបានចុះបញ្ជីភាគហ៊ុនរបស់ខ្លួនជាមួយទីផ្សារកំណើននៃផ្សារមូលបត្រកម្ពុជា **"CSX"** ដែលមានមោទនភាពក្នុងការប្រកាសថា ក្រុមហ៊ុនយើងបានទិញដីដ៏ល្អមួយកន្លែងនៅ សង្កាត់ ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ក្នុងគោលបំណងអភិវឌ្ឍន៍សាងសង់គម្រោងខុនដូ **THE GARDEN RESIDENCY 3** នាពេលខាងមុខនេះ។ តម្លៃទិញដីគឺ ៧,៤១០,៦០០,០០០ រៀល។ ទ្រព្យសកម្មសរុបនៅចុងឆ្នាំសារពើពន្ធចុងក្រោយគឺ ៦៥,៣៥៥,៥១១,៨១០ រៀល និង អនុបាតនៃតម្លៃទ្រព្យសកម្មសរុបគឺ ១១,៣៤%។

ក្នុងនាមជាក្រុមហ៊ុនដែលមានកិច្ចខិតខំប្រឹងប្រែង សាងសង់លំនៅដ្ឋានដែលឆ្លើយតបនឹងតម្រូវការរបស់ប្រជាជនកម្ពុជាយើង។ យើងនឹងប្តេជ្ញាផ្តល់នូវគម្រោងប្រកបដោយភាពច្នៃប្រឌិត និង មានគុណភាពខ្ពស់ ដែលលើសពីការរំពឹងទុករបស់ម្ចាស់ភាគហ៊ុនទាំងអស់របស់យើង។ យើងជឿជាក់ថាគម្រោងខុនដូ **THE GARDEN RESIDENCY 3** នឹងមិនត្រឹមតែចូលរួមចំណែកដល់ការរីកលូតលាស់នៃទីផ្សារអចលនទ្រព្យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ឱ្យប្រជាជនកម្ពុជានូវបរិបទនៃការរស់នៅថ្មី ដែលប្រកបដោយជាសុខភាព និង និរន្តរភាពផងដែរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជននិងវិនិយោគិនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ចន្ទ ៨ កើត ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២៣

**ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ជេអេស លែន ភីអិលស៊ី
JS LAND PLC.
KINGDOM OF CAMBODIA